ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភា រដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ ៖ ២២៦

ចុះថ្ងៃទី១៩ខែសីហាឆ្នាំ១៩៩៨

សាលដីកា

លេខ ៖ ៧៣

ចុះថ្ងៃទី២០ខែមេសាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ ៖-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ប៉ែន ស៊ិន ជាចៅក្រម

៣- លោក វេវៀល មួន ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម

៥- លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ២៥០ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៨០ ចុះថ្ងៃទី០៥ខែសីហា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះនាង ហង់ យ៉េត អាយុ ៦២ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅពុំ ភូមិ លាបទង ឃុំ កំពង់ចិនខាងត្បូង ស្រុកស្ទោង ខេត្ត កំពង់ធំ .ឪពុកឈ្មោះ ឯក ហង់ " វ " ម្តាយឈ្មោះ សូ ហួន " ស "

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះនាង ម្លួន នឹម អាយុ ៤៤ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅពុំ ភូមិ លាបទង ឃុំ កំពង់ចិនខាងត្បូង ស្រុកស្ទោង ខេត្ត កំពង់ធំ . ឪពុកឈ្មោះ ស៊ូ ម្លួន " ស " ម្តាយឈ្មោះលឹម ហឹម "ស "

កម្មវត្ថុបណ្តឹង ៖ ប្តឹងទាមទារដីលំនៅដ្ឋាន ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី ៣០.៦.១៩៩៨ របស់ឈ្មោះ ហង់ យ៉េត ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៥០ ចុះថ្ងៃទី ២៦.៥.១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២៦ ចុះថ្ងៃទី១៩.៨.១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ២៥.០៤.៨៣ របស់ឈ្មោះ ឃួន នឹម ប្ដឹងសុំអោយឈ្មោះ ហង់ យ៉េត រុះរើរបងដើម្បីអោយខ្លួនគ្រប់គ្រងដីដោយហេតុថា កាលពីឆ្នាំ ១៩៧៩ ខ្លួនបានមករស់នៅលើដីនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១២ ចុះថ្ងៃទី ២៣.០៣.១៩៨៤ របស់តុលាការខេត្តកំពង់ធំ សំរេចចំពោះមុខគូក្ដី ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ២៥.៤.៨៣ របស់ដើមចោទឈ្មោះ ឃួន នឹម ទុកជាមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ប្រគល់ដីទំហំ ១៣ម គុណ ៦០ម ដល់មាត់ស្រះស្ថិតនៅភូមិលាបទង ឃុំកំពង់ចិនត្បូង ស្រុក ស្ទោង ខេត្ត កំពង់ធំ ដែលជាដីបំរុងទុករបស់រដ្ឋ អោយទៅឈ្មោះ ឃួន នឹម គ្រប់គ្រងរស់នៅជាបណ្ដោះអាសន្នចាប់តាំងពីពេលនេះតទៅ ។ ហង់ យ៉េត ក៏ត្រូវបានចំណែកស្មើគ្នាដែរ ។

ដាក់កំហុសទៅលើចុងចម្លើយ ។

៣- អោយឈ្មោះ ហង់ យ៉េត រុះរើរបងចេញពីដីឈ្មោះ ឃួន នឹម ជាដើមចោទក្នុងរយៈពេល ១៥ថ្ងៃ ចាប់តាំងពីថ្ងៃនេះតទៅ ។

៤- បង្គាប់អោយឈ្មោះ ហង់ យ៉េត ជាចុងចម្លើយ បង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី ពន្ធហ្នឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់ប្រគល់ដីការកោះ ៥០០០រៀល សរុប ៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទ បានបង់រួចហើយ ផុតកំណត់ឧទ្ធរណ៍ អោយចុងចម្លើយ សងទៅដើមចោទ វិញ ។

៥- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើគូក្ដីណាមិនសុខចិត្ត អាចប្ដឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី២៤.០៣.១៩៨៤ របស់ឈ្មោះ ហង់ យ៉េត ប្ដឹងមិនសុខចិត្តនឹងសាលក្រមលេខ ១២ ចុះថ្ងៃទី ២៣.០៣.៨៤ របស់តុលាការខេត្តកំពង់ធំ លើសេចក្ដីសំរេចទាំងមូល ។

បាន ឃើញសាលដីការបៀបលេខ ១២៥ ចុះថ្ងៃទី ១១.១១.១៩៨៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១- សំរេចចាត់របៀបអោយភ្នាក់ងារភូមិបាលស្រុកស្ទោង អោយចុះទៅពិនិត្យធ្វើអង្កេតដល់ទីកន្លែងដីកើតហេតុនៅចំពោះមុខគូក្ដី គូសផែនទី និង ធ្វើសេចក្ដីកត់ហេតុបញ្ជាក់អោយបានដឹងថា ផ្ទះ និង ដីទំនាស់ដើមចោទកាន់កាប់គ្រប់គ្រងមានបណ្ដោយ ទទឹងប៉ុន្មាន ? ឯចុងចម្លើយកាន់កាប់បណ្ដោយ ទទឹងប៉ុន្មាន ? ម្នាក់ៗ កាន់កាប់ពីឆ្នាំណាដល់ឆ្នាំណា ? តើដីទំនាស់មានតម្លៃប៉ុន្មាន ?

២- ចាត់អោយសួរយកចម្លើយអ្នកដែលមានព្រំដីជាប់គ្នា ឬ អ្នកផ្សេងទៀតដែលបានដឹងឮ អំពីបែងចែក និង កាន់កាប់ដីទីតាំងទំនាស់នេះ ។

---- ៣ ---

៣៧·

៣- បង្គាប់អោយធ្វើអង្កេតគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ដើម្បីរកមូលដ្ឋានម្នាក់ៗ កាន់កាប់ និង គ្រប់គ្រងដីយ៉ាងណាខ្លះ ?

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៥០ ចុះថ្ងៃទី ២៦.០៥.១៩៩៨ របស់សាលាឧទ្ធរណ៍ សំរេចកំបាំងមុខក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤.០៣.១៩៩៤ របស់ដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ ហង់ យ៉ែត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១២ ចុះថ្ងៃទី ២៣.០៣.១៩៩៤ របស់តុលាការខេត្តកំពង់ធំ ទុកជាបានការ ។

៣- សំរេចកាត់យកប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ និង អាជ្ញាធរតុលាការ ១០.០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខក្តី ។ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី ៣០.៦.១៩៩៨ របស់ឈ្មោះ ហង់ យ៉ែត ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៥០ ចុះថ្ងៃទី ២៦.៥.១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ០១.៩.១៩៩៨ របស់ឈ្មោះ ហង់ យ៉ែត ។

បានឃើញសារណាតប ចុះថ្ងៃទី ១៧.១១.១៩៩៨ របស់ឈ្មោះ ឃួន នឹម ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :-

ដីទំនាស់ពិតជាដីបំរុងរបស់រដ្ឋ ដែលមិនអាចប្រគល់សិទ្ធិផ្តាច់មុខទៅអោយជនណាម្នាក់បានទេ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ហង់ យ៉ែត ជាចុងចម្លើយ និង ជាដើមបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: ខ្លួនបានមករស់នៅលើដីនេះតាំងពីឆ្នាំ១៩៧៩ ហើយកន្លងមកដីនេះស្រុក បានផ្លាប់អោយខ្លួនចេញដែរ តែខ្លួនមិនព្រម ហើយក៏រស់នៅលើដីនេះរហូតដល់សព្វថ្ងៃ ឯឃួន នឹម បានចេញរស់នៅកន្លែងផ្សេងដែលបានប្តូរអោយតាំងពីឆ្នាំ ១៩៨៤ លុះដល់ឆ្នាំ ១៩៩២ ប៉ុល ពត វាយស្មាង ទើឆ្លាំងដលផលនេះអស់ពេលនោះ ឃួន នឹម បានមកសុំនៅវិញជាបណ្តោះអាសន្ន ដែលឃួន នឹម បាន មកនៅត្រឹមផ្ទៃដី ៨ , ៤០ម គុណ ១៥ ,៥០ម ប៉ុណ្ណោះ ដែលខ្លួន អនុញ្ញាតអោយនៅ ។តែពេលមានទំនាស់ឈ្មោះ ឃួន នឹម បានទាមទាររហូតដល់បណ្តោយប្រវែង ៦០មទៅវិញ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឃួន នឹម ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: ដីនេះជាដីរបស់ខ្លួនទេ ហើយដីខ្លួន និង ហង់ យ៉ែត គឺមានទទឹងដូចគ្នា



៧៣-

ខ្លួន សុំប្តឹងទាមទារតែដីរបស់ខ្លួននៅ ហង់ យ៉េត ដែលកាន់កាប់នោះទេ ខ្លួនមិនមែនសុំដីរបស់គាត់ទេ ហើយពេលដលផលដេញខ្លួន ក៏ចេញតែក្រោយមកខ្លួន ក៏សុំប្រធានភូមិនៅវិញ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុ លា កា រ កំ ពូ ល

~~~~~~~~~~

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី ៣០.៦.៩៨ របស់អ្នកស្រីហង់ យ៉េត ស្ថិតក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និង ចុងចម្លើយ ពិតជាបានរស់នៅលើដីបំរុងរបស់រដ្ឋប្រាកដមែន ។

- យល់ឃើញថា ថ្វីបើដីទំនាស់ជាដីរបស់រដ្ឋក៏ពិតមែន ក៏ប៉ុន្តែកន្លងមកដើមចោទ និង ចុងចម្លើយ ធ្លាប់បានកាន់កាប់គ្រប់គ្រង និង រស់នៅតាមចំណែករៀងៗខ្លួនរួចហើយ ដូច្នេះការដែលចុងចម្លើយ ទាទយកដីរបស់ដើមចោទនោះជាការរំលោភលើសិទ្ធិរបស់ដើមចោទ ។

- យល់ឃើញថា ដីទំនាស់ជាដីបំរុងរបស់រដ្ឋដែលគ្រប់គ្រងដោយការិយាល័យដលផលស្រុក ស្មោង ប៉ុន្តែដោយការិយាល័យដលផលនេះពុំបានប្តឹងទាមទារនោះគប្បីអនុញ្ញាតិអោយគូភាគីប្រើប្រាស់ជាបណ្តោះអាសន្នតាមចំណាំដែលធ្លាប់បានប្រើពីមុនមកបន្តទៀត ។

- យល់ឃើញថា ខ្លឹមសារនៃសារណារបស់គូភាគីជារឿងនៃអង្គហេតុដែលតុលាការថ្នាក់ក្រោម បានពិចារណាសព្វគ្រប់ហើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៥០ ចុះថ្ងៃទី ២៦.៥.៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ៕

ហេ តុ ដូ ច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

~~~~~

១- ទទួលបណ្តឹងសាទុក្ខលេខ ២៥៥ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី ហង់ យ៉េត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ២៥០ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

------ ៥ -----

៣_ រឹបអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រី ឃួន នឹម បង់ជូលនៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ :_

_ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្នឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

_ ចំណាយក្នុងការប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវអោយអ្នកស្រី ហង់ ហ៊ើត សងប្រាក់ ចំនួន ១៩.០០០រៀលនេះទៅអ្នកស្រី ឃួន នឹម វិញ ។

៤_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៩ ។